ក្រសួងអប់រំ យុវជន និង កីឡា

# ១០ ប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍

## បញ្ឈប់ពលកម្មកុមារ

### ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

**វត្ថុបំណង:** បង្កើនការផ្សព្វផ្សាយដើម្បីឱ្យមានការយកចិត្តទុកដាក់ជាសាធារណៈលើបញ្ហាពលកម្មកុមារ។ ការយល់ដឹងពីរបៀបការងារផ្សព្វផ្សាយ។ ការរៀបចំសម្រាប់ការផ្សព្វផ្សាយ និងធ្វើការសម្ភាសន៍តាមវិទ្យុ និងទូរទស្សន៍។





## លទ្ធផលរំពឹងទុក

ពង្រីកសក្តានុពលសម្រាប់បង្កើនការយល់ដឹង និងអប់រំសហគមន៍ព្រមទាំងបង្កើនប្រសិទ្ធិភាពផ្សព្វផ្សាយ។

## ការកំណត់ពេលវេលា

បង្រៀន២ពេលជាប់គ្នា ឬ ២ ពេលដាច់ពីគ្នា

## ហេតុផល

ការធ្វើការងារជាមួយការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ គឺមិនដូចគ្នាជាមួយនឹងការសរសេរសារព័ត៌មានទេ។ ជាសំណូមពររបស់យើង ប្រសិនណា បើអ្នកបានអនុវត្តរួចហើយតាមសៀវភៅសារព័ត៌មាន ក្រុមរបស់អ្នកនឹងបង្កើតឡើងអំពីសារៈសំខាន់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានជាមធ្យោបាយនៃការផ្សព្វផ្សាយអត្ថបទយ៉ាងទូលំទូលាយ និងពង្រីកឥទ្ធិពលនូវអ្វីដែលគេកំពុងព្យាយាមធ្វើ។



សៀវភៅនិយាយពីប្រព័ន្ធផ្សព្វផ្សាយទាំងពីរ សម្លឹងមើលពីរបៀបក្មេងៗដែលអាចចូលរួមក្នុងប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយទៅមនុស្សជាច្រើននៅក្នុងសហគមន៍អំពីដែលពួកគេកំពុងធ្វើអំពីមូលហេតុ និងរបៀបដែលសហគមន៍អាចជួយបាន។ ពួកគេបានធ្វើឱ្យទាក់ទងគ្នាយ៉ាងល្អជាមួយសៀវភៅដទៃទៀតដូចជានិពន្ធរឿងការអង្កេត និងការសម្ភាសន៍។

សារៈប្រយោជន៍ដ៏ធំនៃជំពូកផ្សព្វផ្សាយទាំងនេះគឺ អាចឱ្យពួក

ក្មេងៗអនុវត្តបំណិន និងសមត្ថភាព ដែលគេកំពុងអភិវឌ្ឍន៍មកដល់ពេលនេះ ។ វាគឺជាជំហានមួយទៀតក្នុងការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈរបស់ពួកគេ និងក្នុងដំណើរការទទួលខុសត្រូវ ។ វាបង្កើតពួកគេឱ្យទៅជាភ្នាក់ងារសម្រាប់កំណែនសង្គមជាមួយ និងសហគមន៍ ។

ការងារជាមួយប្រព័ន្ធផ្សព្វផ្សាយគឺ ជាបំណិនដ៏មានសារៈសំខាន់ក្នុងស្ថានភាពសេដ្ឋកិច្ចថ្មីត្រូវផ្សារភ្ជាប់នឹងដំណើង និងការប្រើប្រាស់ព័ត៌មានដែលគ្របដណ្ដប់លើកន្លែងដែលសំខាន់ក្នុងការរស់នៅរបស់ប្រជាជន ។ បំណិននេះនឹងបម្រើក្មេងៗបានល្អក្នុងការសិក្សា និងមុខរបរផ្ទាល់ខ្លួនទៅអនាគតរបស់ពួកគេ និងធានាថាមេរៀនដែលគេបានសិក្សាពីជំពូកទាំងនេះ និងស្ថិតនៅក្នុងជីវិតរបស់ពួកគេជាបន្តបន្ទាប់ទៅអនាគត ។



**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់ :**

យើងសូមផ្ដល់អនុសាសន៍ថា អ្នកគួរតែប្រតិបត្តិទៅលើប្រព័ន្ធផ្សព្វផ្សាយ ដូចជា : ជំពូកសារព័ត៌មានមុនជំពូកនេះ ។ ជំពូកសារព័ត៌មាននឹងត្រូវបង្កើតការជឿជាក់របស់ក្រុមក្នុងការងារជាមួយការផ្សព្វផ្សាយ និងមានការណែនាំដ៏ល្អទៅកាន់ពិភពលោក ។ ដើម្បីវិសាលភាពដ៏ពិតប្រាកដមួយក្មេងៗអាចលាក់បាំងការដឹងពីខ្លួនឯង និងការទុកចិត្តដែលគេប្រហែលជាមានលាក់នៅខាងក្រោយព័ត៌មាន ឬ អត្ថបទដែលគេសរសេរ ។ ទោះជាយ៉ាងណាក៏ដោយការផ្ដល់ការសម្ភាសន៍តាមវិទ្យុ ឬ បង្ហាញមុខសំដែងការជជែកគ្នា តាមទូរទស្សន៍ ឬ មួយដំណើងនៃតំបន់ជុំវិញមិនអនុញ្ញាតិឱ្យបញ្ហានេះនៅតែរក្សាអណាមិកភាព ឬស្វែងរកទីកន្លែងលាក់កំបាំង ។ បន្ថែមទៅលើនេះ ក្រុមអាចប្រើការ ផ្សព្វផ្សាយព័ត៌មានដែលពួកគេបង្កើនក្នុងជំពូកព័ត៌មាននោះ ជាមធ្យោបាយនៃការបង្កើតទំនាក់ទំនងជាមួយ និងស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ។

## ការរៀបចំ

មុនពេលអ្នកចាប់ផ្តើមលើជំពូកនេះ អ្នកត្រូវការពិនិត្យតាមលំដាប់ដូចខាងក្រោមនេះ :

- សម្រេចចិត្តថាតើស្ថានីយ៍វិទ្យុ ឬទូរទស្សន៍អ្វីខ្លះដែលសមស្របទៅលើគម្រោងនេះជាងគេ។ ស្ថានីយ៍តាមមូលដ្ឋានទំនងជាឆ្លើយតបដោយភាពវិជ្ជមានច្រើនជាងចំពោះគោលការណ៍ណាមួយ ប៉ុន្តែមិនមែនទាត់ចោលស្ថានីយ៍ជាតិដែរ។ នៅពេលស្ថានីយ៍មួយ ត្រូវបានគេស្គាល់ ចូរពិនិត្យមើលតើស្ថានីយ៍ទាំងនេះ ផ្សព្វផ្សាយកម្មវិធីអ្វីខ្លះ ហើយជ្រើសរើសយកស្ថានីយ៍មួយ ឬ ពីរដែលសមស្របទៅនឹងគោលបំណងរបស់អ្នក។
- **ការទាក់ទងស្ថានីយ៍ជាមុន** : ការគិតអំពីស្ថានីយ៍ និងកម្មវិធី អ្នកគួរតែធ្វើ ការទាក់ទងជាមួយនឹងអ្នកផលិតកម្មវិធីជាក់លាក់ទាំងនេះ។ បុគ្គលិកស្ថានីយ៍វិទ្យុ ទូរទស្សន៍ត្រូវការជាមុននូវការដាស់តឿនដែលថា ការផ្សព្វ-ផ្សាយព័ត៌មានរបស់អ្នកនឹងចេញមកក្នុងពេលឆាប់ៗនេះ ហើយពួកគេត្រូវការគំនិតយោបល់ថា តើព័ត៌មាននោះនិយាយអំពីអ្វី? ។ ពួកគេត្រូវមានគម្រោងកម្មវិធីពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ហើយដោយសារការទាក់ទងពួកគេមុន អ្នកនឹងអាចមានគំនិតល្អប្រសើរទៀតសម្រាប់ការដាក់ពេលវេលាក្នុងសកម្មភាពនេះ។
- **ការកំណត់ពេលវេលាត្រឹមត្រូវ** : ដំណឹងត្រូវទាក់ទងនឹងសភាពបច្ចុប្បន្នពោលគឺ អ្វីដែលកើតឡើងថ្ងៃនេះ។ និយាយពីគម្រោងរបស់អ្នកពេលដែលវាកំពុងកើតឡើងមិនមែនបន្ទាប់ពីបញ្ចប់ទៅអស់ជាច្រើនសប្តាហ៍នោះទេ។ គឺមានន័យថា ក្នុងនាមជាអ្នកអប់រំ អ្នកត្រូវគិតថា តើពេលណាគួរអនុវត្តជំពូកនេះ។ ចូរធ្វើគម្រោងដោយប្រុងប្រយ័ត្ន។
- **ពេលវេលាកំណត់ចុងក្រោយ**: ត្រូវធ្វើឱ្យប្រាកដថា ស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ទទួលការផ្សព្វផ្សាយព័ត៌មានក្នុងពេលវេលាដ៏សមគួរ ហើយបន្ទាប់មកធ្វើការងារផ្សព្វផ្សាយរួមគ្នាដោយផ្ទាល់ជាមួយអ្នកផលិតកម្មវិធីដោយគោរពពេល វេលាសម្រាប់ធ្វើសម្ភាសន៍។

ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ទាំងឡាយដូចជា សារព័ត៌មាន, សូម្បីតែស្ថានីយ៍

ផ្សព្វផ្សាយតូចៗ ក្នុងស្រុកក៏ជាអង្គភាពដែលមានការមមាញឹកដែរ។ ពួកគេបានបំពេញរលកធាតុអាកាសជាច្រើនរៀងរាល់ថ្ងៃ ហើយពេលវេលារបស់ពួកគេ គឺមានតម្លៃណាស់។ ដូច្នេះហើយផ្លូវដ៏ពិសេស ដើម្បីទទួលចំណាប់អារម្មណ៍របស់ពួកគេ គឺ ធ្វើការងារជាច្រើនរបស់ពួកគេ។ ការងារផ្សេងទៀតរៀបចំការផ្សព្វផ្សាយដែលអាច ប្រើជាមូលដ្ឋានសម្រាប់ការពិភាក្សា ឬ សម្ភាសន៍ និងអនុវត្ត បន្តតាមលំដាប់ដោយទាក់ទងផ្ទាល់ជាមួយស្ថានីយ៍វិទ្យុ។ ប្រសិនបើអ្នកធ្វើការងារ ជាច្រើននៅក្នុងស្រុកសម្រាប់ពួកគេ ចំណាយពេលវេលាជាមួយពួកគេតាមទូរស័ព្ទផ្នែករបស់អ្នកទំនងជាត្រូវបានបង្ហាញជាសាធារណៈច្រើនជាង។



### ការគាំទ្រខាងក្រៅ

ប្រសិនបើអ្នកមានមិត្តរួមការងារដែលមានបទពិសោធជុំវិញអ្នក ហើយចង់ចូលខ្លួនជួយអ្នកក្នុងការប្រតិបត្តិការលើជំពូកនេះ ចូរទទួលយកការគាំទ្រនេះដ៏ពេញលេញទៅចុះ។ អ្នកប្រហែលជាដឹងពីបញ្ហាផ្ទាល់ខ្លួនរបស់អ្នកណាម្នាក់ផងដែរ ប្រហែលជាសូម្បីតែឪពុកម្តាយរបស់ក្មេងណាម្នាក់នៅក្នុងក្រុមរបស់លោកអ្នកក៏ដោយ អ្នកដែលធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយ ឬមានបទពិសោធន៍ខាងផ្សព្វផ្សាយផង ។

ករណីដែលអាចកើតឡើងដែរគឺថា ស្ថានីយវិទ្យុ ឬ ទូរទស្សន៍ក្នុងស្រុករបស់លោក អ្នក អាចបញ្ជូនអ្នកណាម្នាក់ឱ្យជួយនៅជំពូកនេះ។ ប្រសិនបើគ្មានអ្វីផ្សេងទៀតទេ ពួកគេប្រហែលជាសុខចិត្តមកជជែកជាមួយក្រុមអំពីការងាររបស់អ្នកកាសែតណាម្នាក់ហើយទទួលពីរបៀបផ្សព្វផ្សាយ។

ក្មេងៗជានិច្ចកាលប្រាកដជាជក់ចិត្តចាប់អារម្មណ៍ទៅលើរបៀបការងារផ្សព្វផ្សាយទាំងនេះ។ ពួកគេប្រហែលជាស្តាប់ព័ត៌មានផ្សព្វផ្សាយតាមវិទ្យុ ឬមើលតាមទូរទស្សន៍បានយ៉ាងល្អ ។

ម្យ៉ាងទៀតអ្នកអាចសុំជំនួយពីអ្នកឯកទេស ឬ ទីប្រឹក្សា ផ្នែកប្រព័ន្ធផ្សព្វផ្សាយនិងទំនាក់ទំនង។ ប្រសិនបើអ្នកមិនស្គាល់ពួកគេអ្នកប្រហែលជាស្វែងរកពួកគេក្នុងតារាងលេខទូរស័ព្ទតាមមូលដ្ឋាន។ ដោយត្រូវបានផ្តល់លក្ខណៈពិសេសចំពោះមុខវិជ្ជានេះ អ្នកគួរតែសាកសួរ ប្រសិនបើគេអាចសំណូមពរពីសេវាកម្មមិនគិតប្រាក់របស់ពួកគេ។

គួរតែចងចាំថា ត្រូវបញ្ចូលពួកក្មេងៗនៅក្នុងក្រុមលោកអ្នកក្នុងការទាក់ទាញការតាំងពីខាងក្រៅ លើកទឹកចិត្ត និងជួយពួកគេដើម្បីទាក់ទង អ្នកផលិតកម្មវិធី ឬ អ្នកដទៃដែលនៅតាម ស្ថានីយវិទ្យុ ទូរទស្សន៍ក្នុងស្រុក។ វាគឺជាបទពិសោធន៍ដ៏ល្អសម្រាប់ពួកគេ និងជាផ្នែកមួយដ៏សំខាន់នៃរបៀបដែលអ្នកគួរតែដោះស្រាយជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ។ សំបុត្រផ្សេងៗទៀតផ្ញើទៅកាន់ប្រព័ន្ធផ្សព្វផ្សាយគួរតែធ្វើជាបន្តទៀតជាមួយនឹងការទាក់ទងតាមទូរស័ព្ទ។

## អ្វីដែលអ្នកត្រូវការ



- ✓ ការចេញផ្សាយព័ត៌មានត្រូវបានធ្វើឡើងក្នុងជំពូកសារព័ត៌មាន
- ✓ ក្ដារខៀនសរសេរដីស និងក្ដារខៀនសរសេរហ្វឺត ឬ ផ្ទាំងផ្ទត់រូបភាព
- ✓ ប្រើប្រាស់ទូរស័ព្ទ ប្រសិនបើអាច ប៉ុន្តែមិនចាំបាច់ទេ
- ✓ ប្រដាប់ថតវីដេអូ កាសែតវីដេអូ និងការត្រួតពិនិត្យទូរទស្សន៍

(**កំណត់សំគាល់** : ប្រភេទសំភារៈនេះ គឺ មិនមែនជាមធ្យោបាយសំខាន់ទាល់តែសោះព្រោះមានតម្លៃថ្លៃ ហើយមិនអាចរកប្រើប្រាស់បាននៅក្នុងគ្រប់ស្ថាប័ននិងសហគមន៍ទាំងឡាយឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើលោកអ្នកមានសំភារៈប្រើប្រាស់បែបនេះ ប្រើវាទៅ)។







## ការចាប់ផ្តើម

របៀបដែលចាប់ផ្តើមអំពីការប្រតិបត្តិជំពូកនេះ ត្រូវផ្អែកលើកត្តាផ្សេងៗដូចតទៅ :

- ថា តើអ្នកអាចអញ្ជើញវាគ្មិនម្នាក់(វាគ្មិនទាំងឡាយ) ពី ប្រព័ន្ធផ្សព្វផ្សាយបាន ឬ មិនបាន ។
- ថាតើមានមិត្តរួមការងារគ្រូម្នាក់ផ្សេងទៀត ឬ បុគ្គលដែលនឹងជួយអ្នកដើម្បីផ្សព្វផ្សាយមេរៀននេះ ឬទេ ។
- ថាតើមានការដឹកនាំមេរៀននេះខ្លួនឯង ឬក៏មិនអាច ។ ទោះជាក្នុងករណី ណាក៏ដោយ គោលការណ៍ពិពណ៌នាខាងក្រោមនេះ គួរតែល្អមអាចធ្វើឱ្យអ្នកប្រតិបត្តិជំពូកនេះដោយខ្លួនឯង ជាមួយបទពិសោធន៍ ។ មិនបាច់មានបទពិសោធន៍ពីមុនក្នុងផ្នែកនេះក៏បាន ។

ដូចនេះគួរតែអនុវត្តជាបន្តពីជំពូកសារព័ត៌មាន ដោយរក្សាក្រុមតូចៗដដែល ។ មានការចូលរួមសរសេរក្នុងកាលវិភាគទៅលើការផ្សព្វផ្សាយសារព័ត៌មាន និងការបង្កើតសំណួរសម្ភាសន៍ ។ បន្ថែមពីលើនេះនឹងមានការសម្តែមួយចំនួនជាក់លាក់ព្រោះក្រុមត្រូវសម្តែងឱ្យដូចការសម្ភាសន៍ក្នុងវិទ្យុ និងទូរទស្សន៍ទាំងឡាយ ។ លំហាត់ទាំងនេះនឹងជួយបង្កើតជំនឿជឿជាក់ ដែលក្មេងៗត្រូវការ ។ មុនពេលគេធ្វើសកម្មភាពទាក់ទងយ៉ាងពិតប្រាកដជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ ។

ប្រសិនបើអ្នកប្រតិបត្តិ ការសម្តែងតួ ឬជំពូកដដែកតទល់រួចរាល់ហើយ អ្នកគួរតែបែងចែក អ្នកដែលធ្វើសកម្មភាពបានល្អឬអ្នកថ្លែងការជាសាធារណៈ ។ ព្យាយាមនិងធ្វើឱ្យប្រាកដថា បុគ្គលទាំងនេះមិនមែននៅក្រុមជាមួយ



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

យើងសូមសំណូមពរថា អ្នកគួរជ្រើសរើសធ្វើការជាមួយឧបករណ៍ផ្សព្វផ្សាយមួយ ឬ អ្វីផ្សេងទៀត នៅក្នុងជំពូកនេះ គឺថា ទាំងវិទ្យុ ឬ ទូរទស្សន៍ ។ ឬក៏ប្រសិនបើអ្នកចូលចិត្ត ឬ ប្រសិន បើក្រុមចូលចិត្តអ្នកគួរអនុញ្ញាតិឱ្យពួកគេសម្រេចចិត្តថា តើពួកគេរៀបចំសម្តែងតួសម្ភាសន៍របស់ពួកគេ ដូចជាការសម្ភាសន៍ក្នុងទូរទស្សន៍ ឬវិទ្យុ ។ វាអាចជាការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការ យល់ដឹងពីរបៀប ដែលក្រុមរៀបចំក្រុមផ្សេងៗ គ្នាពីឧបករណ៍ផ្សព្វផ្សាយមួយ ឬផ្សេងទៀត ដើម្បីផ្ទៀងផ្ទាត់ ការរៀបចំក្រុមទាំងនេះទៅក្នុងការពិភាក្សាចុងក្រោយ

## ការរៀបចំក្រុម



គ្នាទាំងអស់នោះទេ ។ ប៉ុន្តែនោះពួកគេត្រូវបានបែងចែក ចូលក្នុងក្រុមផ្សេងៗ ទៀត ដូច្នេះហើយបំណិនរបស់ពួកគេអាចជួយអ្នកផ្សេងទៀតបាន ។ ពួកគេប្រហែលទទួលរ៉ាប់រងតួនាទីជាអ្នកដឹកនាំមួយនៅក្នុងក្រុមតូចៗរបស់ពួកគេដែលអាចមានប្រយោជន៍ចំពោះអ្នក ។

## ការរៀបចំឆាក

*បង្រៀនមួយពេល*

ប្រសិនបើលោកអ្នកទាក់ទងអ្នកសារព័ត៌មាន ឬ អ្នកតំណាងឱ្យវិទ្យុឬទូរទស្សន៍ផ្សេងទៀតបានជោគជ័យ វាជាចំណុចចាប់ផ្តើមល្អមួយនៃជំពូកនេះ ។ អញ្ជើញមនុស្សម្នាក់ឱ្យថ្លែងទៅកាន់ក្រុមមុនពេលដែលអ្នកចាប់ផ្តើមសកម្មភាពបង្រៀនផ្សេងៗ ។ វាអាចជួយយើងក្នុងការរៀបចំឆាកខ្លីៗ ដើម្បីបង្ហាញពីគោលបំណងមេរៀន និងធ្វើឱ្យវាចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើប្រធានបទក្នុងក្រុម ។ លើកទឹកចិត្តដោយដាក់សំណួរ និងចម្លើយមេរៀននៅចុងបញ្ចប់នៃការបង្រៀន (ការបង្ហាញ) ដោយការសួរសំណួរដែលបានរៀបចំ ដោយខ្លួនឯងមុនគេ ។ ក្មេងៗប្រហែលជាមិនអាចឆ្លើយសំណួរ៣-៤ ភ្លាមបានទេ ។ ពួកគេប្រហែលជាមានអារម្មណ៍ស្ទាក់ស្ទើរ រុញរាអំពីការសួរសំណួរ ទោះបីជាគេមានសំណួរខ្លះសម្រាប់សួរក៏ដោយ ។ ដូច្នេះត្រូវជំរុញការចាប់ផ្តើមជាមួយនឹងការសួរសំណួរផ្ទាល់ខ្លួនខ្លះៗ ហើយប្រហែលជាអាចជំរុញភាពជោគជ័យដល់ក្រុម ដែលពួកគេទុក ចិត្តមានជំនឿជឿជាក់ពីការសួរសំណួររបស់ខ្លួន ។

អ្នកគួរតែប្រាកដថា សំបុត្រថ្លែងអំណរគុណត្រូវបានផ្ញើទៅដល់ វាគ្មិនបន្ទាប់ពីការសួរសុខទុក្ខរបស់គេផងដែរ ។ វាគឺជាបញ្ហាសុជីវធម៌ដែលគ្រប គ្នាត្រូវធ្វើ ប៉ុន្តែក៏មិនអាចធ្វើដោយគ្មានការដឹងឮពីវាគ្មិនទេ ។ ការខំប្រឹងប្រែងដ៏តូចតាចនេះជានិច្ចកាលត្រូវបានគេទទួលទុកក្នុងចិត្តវានឹងមានន័យថា បុគ្គលដែលពាក់ព័ន្ធនឹងបើកចំហរដល់ការស្នើសុំជំនួយគាំទ្រនាពេលអនាគត ។

ប្រសិនបើយើងមិនអាចទាក់ទងភ្ញៀវ ដែលជាវាគ្មិនការសំខាន់គឺថា អ្នកចាប់ផ្តើមសម្រាប់ក្រុម ដូច្នេះពួកគេមានការយល់ដឹងអំពីពិភពប្រព័ន្ធផ្សព្វផ្សាយបានប្រសើរជាងមុន ។



វិទ្យុជានិច្ចកាលត្រូវបានចាត់ទុកជាប្រព័ន្ធផ្សព្វផ្សាយមួយ មិនសូវល្អជាងទូរទស្សន៍ ដោយសារតែតួនាទីរបស់ទូរទស្សន៍មានភាពលឿនរហ័សព័ត៌មានផ្សព្វផ្សាយពីសង្គមក្នុងពេលបច្ចុប្បន្នមានប្រសិទ្ធភាព។

ក្មេងៗបានកំណត់យកកម្មវិធីទូរទស្សន៍ជាមូលដ្ឋាននៃគោលការណ៍តម្លៃ និងសូម្បីតែការប្រព្រឹត្តិរបស់ពួកគេនៅក្នុងសង្គមក៏ត្រូវពឹងផ្អែកលើកម្មវិធីទូរទស្សន៍ដែរ។

កម្មវិធីទូរទស្សន៍នាពេលបច្ចុប្បន្នមួយចំនួនដ៏សំខាន់ គឺមានគោលបំណងទៅលើក្មេងជំទង់។ ជាលទ្ធផលក្នុងប្រទេសខ្លះវិទ្យុមិនមែនជានិច្ចកាលសុទ្ធតែត្រូវបានបង្ហាញយ៉ាងឆាប់រហ័សថាជាការផ្សាយព័ត៌មានកំពុងពេញនិយមឡើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយវាជាគន្លឹះនៃប្រព័ន្ធផ្សព្វផ្សាយមួយ។

វិទ្យុមានគុណសម្បត្តិគួរឱ្យកត់សំគាល់ច្រើនជាងទូរទស្សន៍ត្រង់ថាវាថោកហើយស្រួលទទួលជាង។ ប្រជាជនស្តាប់វិទ្យុ២៤ម៉ោងក្នុង១ថ្ងៃ,៧ថ្ងៃ ក្នុង១សប្តាហ៏៣៦៥ថ្ងៃក្នុង១ឆ្នាំ ពួកគេកំពុងតែស្តាប់វិទ្យុដូចជាវាក្លាយទៅជាផ្នែកមួយក្នុងជីវភាពសព្វថ្ងៃរបស់ពួកគេ។ ផ្ទះភាគច្រើននិងទីកន្លែងធ្វើការជា ច្រើនមានវិទ្យុមួយក្នុងបរិវេណទាំងនោះ។ ក្នុងប្រទេសដែលផ្ទះខ្លះគ្មានអគ្គិសនី ហើយប្រជាជនគ្មានមធ្យោបាយទិញទូរទស្សន៍ និងក្នុងប្រទេសខ្លះដែលមានអនក្ខរភាពជាបញ្ហាមួយចោទនោះ វិទ្យុជាប្រភពជាប់ចំណាត់ថ្នាក់លេខ១ ក្នុងការផ្តល់ ព័ត៌មាន, ទំនាក់ទំនង និងការកំសាន្ត។ កម្មវិធីវិទ្យុ និងទូរទស្សន៍ បានផ្តល់យ៉ាងទូលំទូលាយនូវភាពខុសប្លែកគ្នានៃកម្មវិធីបញ្ចូលទាំងការផ្សព្វផ្សាយព័ត៌មាន និងលក្ខណៈពិសេសពីការបង្ហាញការនិយាយបញ្ជូនតាមទូរស័ព្ទ កម្មវិធីរបស់សាលា កម្មវិធីជាក់លាក់ សម្រាប់ក្រុមដូចជាស្ត្រី និងកុមារ ហើយនិងកម្មវិធីផ្សេងៗទៀត។ អ្នក និងក្រុមគួរតែគិតអំពីកម្មវិធីសម្រាប់ព័ត៌មានស្តីពីគម្រោងរបស់អ្នកដែលសក្តិសម



ទៅនឹងកម្មវិធីជាទីបំផុត។ ជានិច្ចកាលក្មេងៗ ស្តាប់ និងមើលកម្មវិធីដែលផលិតជាពិសេសសម្រាប់ពួកគេដូចជា :
កម្មវិធីយុវវ័យ ការជជែកកំសាន្ត សិល្បៈ ឈុត កំសាន្តខ្លីៗល្បែងល្បងប្រាជ្ញា និងសាលារៀន ឬ កម្មវិធីស្តីពីការអប់រំប្រសិនបើគេនៅសាលារៀន។ អ្នកគួរតែចងចាំផងដែរ ចំពោះស្ថានីយ៍វិទ្យុក្នុងស្រុក គឺពេញនិយម ហើយត្រូវបានគេស្តាប់ជាញឹកញាប់ជាងវិទ្យុជាតិខ្លះ ដោយសារភាពគ្របដណ្តប់ និងដំណឹងទាំងឡាយ អាកាសធាតុ និងព្រឹត្តិការណ៍ផ្សេងៗ។ វិទ្យុក្នុងស្រុកគួរតែជាកន្លែងដ៏ល្អជាទីបំផុតសម្រាប់ក្រុមរបស់អ្នកចាប់ផ្តើមការងារព្រោះថា ស្ថានីយ៍ទាំងនេះជានិច្ចកាលស្វែងរក រឿងល្អៗក្នុងស្រុក ដើម្បីបំពេញការផ្សព្វផ្សាយតាមរលកធាតុអាកាសរបស់ពួកគេ។

## សកម្មភាព១
## ការសម្ភាសន៍តាមវិទ្យុ ឬតាមទូរទស្សន៍
## បង្រៀនពីរពេលជាប់គ្នា

ទម្រង់នៃការគ្រប់ដណ្តប់របស់វិទ្យុ និងទូរទស្សន៍មានប្រសិទ្ធិភាពជាងគេបំផុត គឺសម្ភាសន៍ហើយជំពូកនេះត្រូវធ្វើឡើង ដើម្បីរៀបចំក្មេងៗសម្រាប់ផ្សព្វផ្សាយ។ លទ្ធផលនៃការផ្សព្វផ្សាយជំពូកនេះនឹងធ្វើសកម្មភាពជាមូលដ្ឋានសម្រាប់ការប្រតិបត្តិទៅលើសកម្មភាពទាំងនេះ។ ក្រុមនីមួយៗ គួរមានក្រដាសថតចម្លងមួយសន្លឹកអំពីការចេញផ្សាយព័ត៌មាន ហើយគេនឹងសន្មត់ថា ការចេញផ្សាយនេះត្រូវបានផ្ញើទៅកាន់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ក្នុងស្រុក។ គោលបំណង គឺបង្កើនលំហាត់ដើរតួរនៅក្នុងក្រុមតូចដែលនឹងត្រូវវិភាគទៅលើការផ្សព្វផ្សាយ បន្ទាប់មករៀបចំជាលំដាប់សំណួរដែលប្រហែលជាត្រូវសួរអំពីអ្នកទាំងឡាយដែលចូលរួមនៅក្នុងគម្រោង ហើយបន្ទាប់មកបង្កើនការឆ្លើយតបចំពោះសំណួរទាំងនេះ ។



**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់ :**

មិនបាច់អនុវត្តជំពូកសម្ដែងតួមុនជំពូកនេះទេ ។ ចំនួននៃការដើរតួសំខាន់នៅក្នុងសកម្មភាពនេះ គឺមិនមែនខ្លាំងក្លាដូចជំពូកសម្ដែងតួខ្លួនឯងដែលដើរមុនច្រើនជាងជំពូកសិល្បៈឡើយ ។ ប្រសិនប្រើអ្វីៗសម្ដែងតួនៅក្នុងជំពូកផ្សព្វផ្សាយអាចសម្ដែងធ្វើជាការណែនាំចំពោះការសម្ដែងតួក្នុងជំពូកនេះ ។ ដូច្នេះហើយ មិនត្រូវការបារម្ភច្រើនអំពីបំណិនសម្ដែងដែលជាប់ទាក់ទងក្នុងវគ្គនោះពេកទេ ។

**បច្ចេកទេសសម្ភាសន៍**

ចាប់ផ្ដើមជាមួយការពិភាក្សាទូទៅក្នុងក្រុម ។ សរសេរលើក្ដារខៀនបន្ទាប់ពីមានក្បួនជាមូលដ្ឋាន ក្នុងការរៀបចំសម្រាប់ការសម្ភាសន៍ក្នុងវិទ្យុ និងទូរទស្សន៍មានដូចជា :

- **រៀបចំ! រៀបចំ! រៀបចំ!** ការសម្ភាសន៍ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយអាចជួបប្រទះអារម្មណ៍ញាប់ញ័រ ទោះបីជាអ្នកទាំងនោះធ្លាប់ធ្វើការនោះក៏ដោយ ដោយសារការរៀបចំខ្លួនសម្រាប់ការសម្ភាសន៍ លោក-អ្នកនឹងអាចជួយរៀបចំគំនិតថ្មីបានងាយស្រួលឱ្យគេផ្ដោតអារម្មណ៍ទៅនឹងមុខងារចម្បងនៃការទទួលសារ ឆ្លងកាត់របស់គេ ។



- **មកដល់ទាន់ពេល :** ជារឿយៗអ្នកដែលត្រូវគេសម្ភាសន៍អង្គុយក្នុងការិយាល័យសម្រាប់ទីកន្លែងរបស់ពួកគេ ។ ប្រសិនបើអ្នកមិនបានអង្គុយនៅកន្លែងរបស់អ្នក អ្នកមិនអាចទទួលឱកាសជាលើកទីពីរយ៉ាងងាយទេ ។ លើសពីនេះទៅទៀតកុមារ នឹងត្រូវការពេលវេលាដើម្បីសម្រេចដោយស្ងប់ស្ងាត់របស់ពួកគេមុនពេលផ្សព្វផ្សាយ ។
- **តើរឿងអ្វី ?** ជាដំណឹងដែលមានតម្លៃគួរផ្សព្វផ្សាយក្នុងវិទ្យុ ឬ ទូរទស្សន៍ការសម្ភាសន៍របស់អ្នកគួរតែទាក់ទង និងរឿងមួយ ។ លោក-អ្នកចង់ទទួលបាននូវការចាប់អារម្មណ៍របស់អ្នកស្ដាប់នៅនឹងកន្លែង ហើយអ្នកគួរតែគិតពិចារណាដោយការស្ដាប់ ។
- **ប្រាប់ដល់ពួកគេថា ពួកគេជាអ្នកណា?:** វាមានសារៈសំខាន់ណាស់ដែលអ្នកស្ដាប់ស្គាល់ច្បាស់ថា អ្នកជាអ្នកណា គឺដើម្បីដាក់រឿងរបស់អ្នកចូលក្នុងបរិបទ ។

- **ការនិយាយដោយប្រើប្រយោគធម្មតាខ្លីៗ** : កុំនិយាយគ្មានប្រធានឥតចុង ឥតដើមវែងអន្លាយក្នុងការសម្ភាសន៍តាមវិទ្យុ ។ និយាយឱ្យច្បាស់ ហើយល្អ កុំនិយាយដដែលៗ ម្យ៉ាងទៀតពន្យល់ហើយបន្តទៅមុខទៀត ។
- **ចៀសវាងនិយាយច្រចូកច្របល់ និងប្រើគ្រាមភាសា:** អ្នកមិនមានបំណង ធ្វើឱ្យបាត់បង់ អ្នកស្តាប់ ឬ ទុកគេចោលដោយសារតែគេមិនយល់ពីចិត្តអ្នក នោះទេ ក្មេងៗត្រូវមានចិត្តចង់ប្រើប្រាស់ភាសាផ្ទាល់របស់ពួកគេ ដូច្នេះ ហើយ ត្រូវហ្វឹកហ្វឺនពួកគេក្នុងការទទួលព័ត៌មានឱ្យច្បាស់ ។
- **សម្រេចចិត្តថាតើព័ត៌មានអ្វីដែលអ្នកចង់បានតាមការសម្ភាសន៍** ការសម្ភាសន៍ដ៏ល្អមួយត្រូវតែវិនិច្ឆ័យទៅលើថា តើអ្នកទទួលបានព័ត៌មាន ឬ អត់ ។ ទោះជាយ៉ាងណាក៏ដោយគម្រោងត្រូវតែល្អ តើព័ត៌មានអ្វីខ្លះដែលអ្នក ចង់បង្ហាញ? រៀបចំតារាងប្រហែល៥ចំណុចសំខាន់ៗដែលអ្នកចង់ធ្វើក្នុង ការសម្ភាសន៍ និងទោះជាមានអ្វីកើតឡើងក៏ដោយ អ្នកត្រូវឱ្យប្រាកដថា អ្នក ទទួលព័ត៌មានបានយ៉ាងហោចណាស់ម្នាក់ក្នុងចំណោមពួកគេអាចធ្វើឱ្យ ប្រាកដថា មនុស្សដែលត្រូវការអរគុណ គឺ អរគុណ ។ ល្បិច គឺដើម្បីបកប្រែ សំណួរក្នុងរបៀបដូចជាសម្ភាសន៍និយាយឱ្យប្រាកដអ្វីដែលអ្នកចង់និយាយ អ្នកមិនចង់រំខាន ប្រសិនបើអ្នកនិយាយល្អ ហើយច្បាស់ ។
- **បញ្ចូលស្ថិតិដែលត្រូវប្រតិបត្តិ** : មានស្ថិតិដ៏គួរឱ្យភ្ញាក់ផ្អើលញាប់ញ័រ ស្តីពី ពលកម្មកុមារជាច្រើន ដែលអ្នកអាចប្រើវាដើម្បីបញ្ជាក់បន្ថែមនូវចំណុចមួយ ឱ្យច្បាស់លាស់ ។ ការសម្ភាសន៍ក្នុងវិទ្យុនឹងត្រូវអស់ពេលច្រើននាទី, ច្រើន វិនាទី ហើយវិធីដ៏ពិតប្រាកដមួយសម្រាប់ទាក់ទាញអារម្មណ៍អ្នកស្តាប់គឺ ត្រូវ រំឭកដល់ពួកគេខ្លះ ។ ទាក់ទងបញ្ហានេះទៅលើស្ថានភាពរៀងរាល់ថ្ងៃ ដើម្បី ធ្វើឱ្យមនុស្សត្រូវតែគិតអំពីអ្វីដែលអ្នកកំពុងនិយាយ ។
- **ត្រូវដឹងថាលោក-អ្នកកំពុងត្រូវបានគេមើល** : កត្តាសំខាន់មួយដែលគួរ ចងចាំចំពោះការសម្ភាសន៍ក្នុងទូរទស្សន៍ជាការពិត គឺការបង្ហាញលក្ខណៈ ផ្ទាល់ខ្លួន ។ អ្នកអាចត្រូវបានគេមើលឃើញទាំងស្រុងក្នុងពេលសម្ភាសន៍ទាំង មូលដូច្នេះ ហើយកាយវិការមានសារៈសំខាន់ខ្លាំងណាស់ដែរ ។ កុមារគួរតែ ប្រុងប្រយ័ត្នដោយកុំសម្តែងកាយវិការនៅឱ្យស្ញៀម ឬអង្គុយដូចជាគ្មាន



សរសៃរកេះសក់ ឬមុខ។ ពួកគេគួរមានទឹកមុខធូរស្រាល និងអនុញ្ញាតិឱ្យដៃរបស់គេបានសម្រាកយ៉ាងស្រួល។ ប្រភេទតារាងខាងលើនេះ គឺនៅក្នុងលំដាប់មួយដែលអ្នកគិតថា បានទាក់ទងខ្លាំងជាងគេសម្រាប់អ្នក និងក្រុមរបស់គេ។ លោក អ្នកប្រហែល ជាមិនចង់និយាយទាក់ទងដល់ចំណុចទាំងអស់ ដូច្នេះហើយ គ្រាន់តែជ្រើសរើសយកមួយណាដែលអ្នកចង់ពិភាក្សា អ្នកគ្រាន់តែសរសេរ ឃ្លាគូសចំណាំ លើ ក្តារខៀន។ ពេលដែលអ្នកមានតារាងលើក្តារខៀន ហើយអ្នកគួរចាប់ផ្តើមត្រួតពិនិត្យមើលចំណុចនីមួយៗម្តងមួយៗដោយនិយាយឱ្យពិស្តារនូវអ្វីដែលបានចូលមកពាក់ព័ន្ធ។

អនុញ្ញាត្តិឱ្យក្រុមរបស់អ្នកសួរសំណួរនៅពេលអ្នកត្រួតពិនិត្យមើលតារាងលើក្តារខៀន។ ត្រូវប្រាកដថា ពួកគេបានយល់ពីចំណុចសំខាន់ៗគោលការណ៍ជាមូលដ្ឋានក្នុងការចូលរួមការសម្ភាសន៍។សួរសំណួរអំពីពួកគេផង ដើម្បីធ្វើឱ្យខ្លួនអ្នកប្រាកដថា គេពិតជាយល់មែន។ ចូររក្សានូវអារម្មណ៍របស់ពួកគេដោយលាយឡំបញ្ចូលការបង្ហាញរបស់អ្នកជាមួយនឹងសំណួរ និងឧទាហរណ៍ជាច្រើន។

## ការរៀបចំបទសម្ភាសន៍

លំហាត់ គឺត្រូវឱ្យក្រុមតូចៗរួបរួមចូលគ្នា ហើយកសាងនូវការបកស្រាយសម្តែងតួរក្នុងការសម្ភាសន៍តាមវិទ្យុ។ គំនិតគឺ រៀបចំក្រុមឱ្យងាយស្រួលធ្វើកិច្ចការទាំងការសម្ភាសន៍ និងការដែលត្រូវគេសម្ភាសន៍ អ្នកគួរតែច្បាស់ថា អ្នកមានចំនួនក្រុមដ៏ទៀងទាត់។ បន្ទាប់មករៀបក្រុមជាដៃគូរ ដូច្នេះពួកគេនៅក្នុងក្រុមពីរដែលមានគ្នាពីរនាក់។ ក្រុមទាំងពីរមានកិច្ចការផ្សេងៗគ្នាដូចតទៅ :

- ក្រុមមួយត្រូវសម្តែងតួជាអ្នកសម្ភាសន៍មកពីស្ថានីយ៏វិទ្យុ។ពួកគេត្រូវរៀបចំសំណួរសម្រាប់សម្ភាសន៍ សម្រាប់ផ្សព្វផ្សាយព័ត៌មាន គឺនឹងត្រូវការមើលឱ្យច្បាស់ពីការផ្សព្វផ្សាយនេះ។ កុំសួរសំណួរទាំងនោះច្រើនពេក ព្រោះពួកគេអាចនឹងយល់ថា ការងារនោះធ្វើឱ្យគេធុញទ្រាន់។ ស្នើសុំឱ្យពួកគេបង្កើតសំណួរល្អៗប្រហែលចំនួន៦ ដែលពួកគេចង់សួរអ្នកណាម្នាក់ ប្រសិនបើគេជាអ្នកសម្ភាសន៍។ ពន្យល់ពួកគេថា ចម្លើយសំណួរគួរបង្កើតឡើងតាមរបៀបដែលអនុញ្ញាតិឱ្យមនុស្សដែលត្រូវគេសម្ភាសន៍ពង្រីកចម្លើយ

តបពួកគេ។ លំដាប់នៃសំណួរឆ្លើយ " បាទ ឬ ចាស" អាចគ្មានលទ្ធផលក្នុងការបង្កើតឱ្យមានការសម្ភាសន៍ដែលគួរឱ្យចាប់អារម្មណ៍ ហើយអ្នកស្តាប់នឹងលែងស្តាប់ ឬគិតគូរមិនខាន។

- ក្រុមទី២ ត្រូវសម្តែងតួជាអ្នកដែលត្រូវគេសម្ភាសន៍។ ពួកគេត្រូវវិភាគទៅលើការចេញផ្សាយពីការយល់ឃើញខុសៗគ្នាដោយគិតអំពីដំណឹងអ្វីដែលគេចង់ទទួលក្នុងការសម្ភាសន៍។ ពួកគេនឹងត្រូវត្រៀមរៀបចំខ្លួនដើម្បីទទួលការសម្ភាសន៍។



ជាការពិតណាស់ក្រុមដែលចែកជាដៃគូមិនគួរអង្គុយ និង ប្រៀបធៀបការកត់សំគាល់របស់ខ្លួនទេ។ ពួកគេគួរតែធ្វើការក្នុងក្រុមគ្នាពីរ នាក់នោះ និងរក្សាទុកសំណួរព្រមទាំងការកត់សំគាល់ចំពោះខ្លួនឯង។ គោលដៅនៃលំហាត់នេះ គឺលើកទឹកចិត្តជំរុញឱ្យក្រុមគិតអំពីតើប្រភេទសំណួរអ្វីដែលប្រហែលជានឹងសួរដោយអ្នកសម្ភាសន៍ និងរបៀបឆ្លើយតបសំណួរទាំងនេះ ករណីនេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលដល់ក្រុមដែលប្រហែលជាបានអញ្ជើញទៅសម្ភាសន៍ក្នុងស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ហើយអាចលើកទឹកចិត្តក្រុមឱ្យគិតយ៉ាងប្រុងប្រយ័ត្នអំពីគម្រោង និងបញ្ហាស្តីពីពលកម្មកុមារ។

អនុញ្ញាតិឱ្យក្រុមរៀបចំខ្លួនប្រហែល២០នាទី សម្រាប់ការសម្ភាសន៍ដាក់សម្ពាធទៅលើពួកគេដោយនិយាយទៅកាន់ពួកគេនៅពេលអ្នកដើរជុំវិញ។ អង្គុយលើតុប្រសិនបើអ្នកឃើញថា សកម្មភាពក្រុមកំពុងតែមានបញ្ហា ឬកំពុងតែតស៊ូស្វិតស្វាញ។ និយាយទៅកាន់ពួកគេអំពីសំណួរដែលគួរសួរដែលបានមកពីការ ផ្សព្វផ្សាយព័ត៌មាន ហើយធ្វើសំណួរដ៏តូចតាចនៅទីនេះ និងទីនោះ។

នៅពេលពួកគេបានចាប់ផ្តើមអ្នកផ្សេងទៀតធ្វើតាមជាបន្តបន្ទាប់ ជាការធម្មតាសំណួរទី១ គឺពិបាកជាងគេ។ ជួយពួកគេឱ្យបន្ធូរអារម្មណ៍ ហើយឱ្យមានភាពងាយស្រួល។

ចូរប្រាកដថា អ្វីៗទាំងអស់គួរតែផ្អែកលើខ្លឹមសារនៃបញ្ហាដែលបានផ្លាស់ប្តូរលើសភាពការណ៍បច្ចុប្បន្ន។ មានការធានាចំពោះពួកគេថា លោកអ្នកមិនចាំបាច់ស្វែងរកផលិតផលដ៏អស្ចារ្យនៅដំណាក់កាលនេះទេ ទិសដៅចម្បងគឺឱ្យក្រុមសរសេរសំណួររបស់ពួកគេ និងរៀបចំខ្លួនសម្រាប់សម្ភាសន៍។ ព្យាយាមធ្វើឱ្យច្បាស់ថា សមាជិកម្នាក់ៗនៃក្រុមតូចៗកំពុងចូលរួមលះបង់ ហើយមិនមែនមានតែបុគ្គលម្នាក់ដែលធ្វើការងារទាំងអស់នេះទេ។

ចូរស្ថិតនៅក្នុងពេលវេលាដែលបានកំណត់ទុករបស់អ្នក ហើយត្រូវធានាឱ្យច្បាស់ថា ក្រុមនីមួយៗត្រូវបំពេញបញ្ចប់នៅក្នុងពេលនោះ។ អ្នកគួរកំណត់ពេលវេលាបញ្ចប់ចំពោះលំហាត់នោះ បើទោះបីជាមិនមាននរណាម្នាក់បានបញ្ចប់ការងារនោះរួចរាល់ក៏ដោយ។

## ហាត់ធ្វើសម្ភាសន៍

នៅពេលបុគ្គលម្នាក់ៗតាំងទីកន្លែង អ្នកគួរតែចាប់ផ្តើមរៀបចំតុនៅកន្លែងខ្ពស់ជាងគេក្នុងបន្ទប់ដើម្បីឱ្យអ្នកគ្រប់គ្នាអាចមើលឃើញផង។ នៅជ្រុងមួយនៃតុគឺ ជាអ្នកសម្ភាសន៍ ហើយជ្រុងផ្សេងទៀតជាអ្នកដែលត្រូវគេសម្ភាសន៍ដោយប្រើមធ្យោបាយប្រជាធិបតេយ្យ ឧទាហរណ៍ ការបោះឆ្នោតឬក៏បោះកាក់ ការបង្កើតតារាងសម្ភាសន៍ជាច្រើនជាដើម។ ប្រសិនបើអ្នកមានម៉ាស៊ីនថតវីដេអូនោះ វាជាលំហាត់ដែលមានប្រយោជន៍ក្នុងការថតចម្លងការសម្ភាសន៍នីមួយៗទុកជាឯកសារ។ អ្នកគួរតែធ្វើការវិភាគឱ្យហ្មត់ចត់ទៅលើបច្ចេកទេសសម្ភាសន៍ទាំងអ្នកសម្ភាសន៍ និងអ្នកដែលត្រូវគេសម្ភាសន៍សម្រាប់ក្រុមដែលរៀបចំសម្ភាសន៍ម្តងទៀតតាមការត្រួតពិនិត្យមួយ។ អ្នកគួរតែជួយក្រុមឱ្យយល់ដឹងនូវអ្វីដែលគួរធ្វើ និងមិនគួរធ្វើនៅក្នុងស្ថានភាពដែលកំពុងធ្វើសម្ភាសន៍នៅលើប្រដាប់ថតវីដេអូ និងបន្ថែមនូវភាពភ័យខ្លាចបន្តិចបន្តួច និងភាពតក់ស្លុតគិតអ្វីមិនឃើញចំពោះលំហាត់សម្តែងតួ។ បញ្ហានេះមានសារៈសំខាន់ដោយហេតុផលជាច្រើន យ៉ាង ៖

- វាធ្វើឱ្យស្ថានភាពកាន់តែពិតថែមទៀត។ អ្នកមិនអាចគេចផុតពីការស្ងប់ស្ងែរ និងរអារពេលដែលត្រូវគេសម្ភាសន៍ ដូច្នេះវាជាប្រការដែល

ជួបប្រទះអារម្មណ៍រំជួលចិត្តទាំងនេះ ហើយដើម្បីយល់ដឹងថា វាមានឥទ្ធិពលទៅលើការសម្តែងរបស់អ្នកយ៉ាងដូចម្តេច ។

- វានឹងជួយណែនាំពីគំនិតនៃការបង្ហាញខ្លួនតាមកញ្ចក់ទូរទស្សន៍ និងការដែលអាចមើលឃើញមិនត្រឹមតែចំពោះអ្នកស្តាប់ក្នុងពេលភ្លាមនេះទេ ប៉ុន្តែអាចមើលឃើញចំពោះទស្សនិកជនដែលយើងមើលមិនឃើញផងដែរ ។

ចូរព្យាយាម និងបង្ហាញការងារថតក្នុងចំណោមក្រុម ដើម្បីឱ្យអ្នកទាំងអស់គ្នាទទួលឱកាសក្នុងការថតកិច្ចសម្ភាសន៍នេះ ។ ពួកគេនឹងសិក្សាពីរបៀបប្រើប្រាស់សំភារៈ និងរបៀបថតឈុតឆាកសម្តែងគួរបែបនេះ ។



ប្រសិនបើអ្នកមិនអាចប្រើប្រាស់សម្ភារៈទាំងនេះបានទេ គឺមិនសំខាន់ឡើយ ។ បញ្ហានៅត្រង់ថា ក្រុមបានចូលរួមក្នុងលំហាត់ទាំងមូល និងចំណេញផលប្រយោជន៍នៃការចូលរួមក្នុងឈុតទាំងនេះ ។

សមាសភាពលំហាត់សំដែងតួនឹងផ្តល់សេវាកម្ម ដើម្បីពង្រឹងបទពិសោធន៍សម្រាប់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើអ្នកអាចទទួលនូវឧបករណ៍ថតសំលេង ។ ករណីនេះអាចជាលំហាត់ដ៏មានប្រយោជន៍លោកអ្នកអាចបង្ហាញផ្នែកខ្លះនៃការសម្ភាសន៍ជាថ្មីម្តងទៀតទៅកាន់មនុស្សដែលចូលរួមដើម្បីជួយពន្យល់អំពីចំណុចដែលលោក អ្នកចង់ធ្វើឱ្យបានច្បាស់លាស់ជាងនេះថែមទៀត ។ វាជាការសិក្សាដកពិសោធន៍ដ៏ល្អមួយសម្រាប់ក្មេងៗទាំងឡាយក្នុងការស្តាប់ការសម្ភាសន៍របស់ខ្លួននឹងបានដឹងឮអំពីរបៀបដែលពួកគេដោះស្រាយ ។ ពួកគេពិតជាមិនបានចុះបញ្ជីនូវអ្វីដែលពួកគេនិយាយជាក់ស្តែងក្នុងកំឡុងពេលធ្វើលំហាត់ ហើយក៏មិនបានកត់ទុកពីរបៀបដែលពួកគេឆ្លើយតបនូវសំណួរដែលត្រូវសួរដែរ ។




រៀបចំក្រុមឱ្យនៅជ្រុងតុណាមួយក៏បាន និងជួយពួកគេឱ្យបន្ទូរអារម្មណ៍ហើយប្តូរទៅសំដែងតួរបស់ខ្លួន ។ ឧទាហរណ៍ឱ្យពួកគេណែនាំខ្លួនទៅវិញទៅមកដោយប្រើឈ្មោះផ្សេងៗគ្នា បង្ហាញ ណែនាំអំពីឯកសារ

ណែនាំអំពីឯកសារ ឬ ផ្តល់ការទស្សន៍ទាយ ពីអាកាសធាតុ ប្រសិនបើពួកគេកំពុងដើរតួជាអ្នកសម្ភាសន៍។ អ្នកទាំងឡាយដែលសាកសួរសំណួរទាំងនោះគួរតែចែករំលែកការទទួលខុសត្រូវមិនគួរជាមនុស្សដដែលៗ ដែលនិយាយគ្រប់ពេលវេលានោះទេ។ ប្រហែលជាសំណួរគួរតែសួរម្តងម្នាក់ទៅអ្នកដែលត្រូវគេសម្ភាសន៍ទាំងពីរ ដូច្នេះហើយគេទាំងពីរនាក់អាចចូលរួមការសម្ភាសន៍នេះបាន។

អ្នកសម្ភាសន៍គួរតែលើកទឹកចិត្តដល់អ្នកដែលត្រូវគេសម្ភាសន៍ពង្រីកចម្លើយរបស់ខ្លួន ហើយប្រសិនបើគេចង់ធ្វើតាមបន្ទាត់សំណួរណាមួយ ដោយផ្អែកលើមូលដ្ឋាននៃចម្លើយដែលឆ្លើយតបរបៀបនេះគួរតែលើកទឹកចិត្តព្រោះជារបៀបដែលបានសម្ភាសន៍ក្នុងវិទ្យុពិតៗ។ ក្រើនរំឭកអ្នកដែលគេសម្ភាសន៍គប្បីចងចាំក្នុងខួរក្បាលនូវសារដែលខ្លួនចង់ធ្វើការទំនាក់ទំនង ហើយព្យាយាមនិងប្រាកដថា ពួកគេធ្វើរបៀបនេះក្នុងកំឡុងពេលសាកសួរសំណួរ។ ជួយធ្វើឱ្យបរិយាកាសធូរស្រាល ។ធ្វើឱ្យការដោះស្រាយលំហាត់មានភាពសប្បាយរីករាយភាពកំប្លុកកំប្លែងគួរតែបង្ហាញនៅគ្រប់កន្លែងដែលគួរបង្ហាញបាន។ ហើយការធ្វើបែបនេះគឺជាការប្រសើរឱ្យតែវាមិនចេញពីមេរៀននៃការសម្ភាសន៍។ ឈរក្បែរក្រុមដើម្បីជួយក្រុមពេលដែលត្រូវគេសួរសំណួរខ្លះៗ។ មានករណីកើតឡើងជាញឹកញាប់ដែលបុគ្គលម្នាក់ប្រហែលជាត្រូវឈប់ស្ងៀមយ៉ាងពិតប្រាកដអារម្មណ៍ភ័យខ្លាចជារឿងសាមញ្ញនៅក្នុងលំហាត់បែបនេះ។ ត្រូវនៅទីនោះដើម្បីជួយពួកគេ ឱ្យចេញពីស្ថានភាពលំបាក ហើយចេញមកបកស្រាយ ដោយភាពថ្លៃថ្នូរ។ នៅពេលក្រុមនីមួយៗ បានបំពេញការសម្ភាសន៍របស់ខ្លួនរួចហើយ ចូរថ្លែងអំណរគុណដល់ពួកគេ ហើយវិលទៅរកក្រុមផ្សេងទៀត រួចសុំឱ្យពួកគេបញ្ចេញយោបល់អំពីការសំដែងដែលពួកគេទើបតែបានទស្សនា។ អ្នកផ្សេងទៀតគួរតែសិក្សាពីអ្វីដែលគេបានឃើញហើយ និងគួររក្សាមេរៀនទាំងនេះនៅក្នុងគំនិតនៅពេលដែលគេដល់វេនសំដែង។ វាមានសារៈសំខាន់សម្រាប់ក្រុមដើម្បីវិភាគការសំដែងទៅវិញទៅមក ហើយវាថែមទាំងជួយឱ្យក្រុមរឹងមាំ ហើយស្វាហាប់ថែមទៀត។ បន្តធ្វើបែបនេះរហូតដល់ក្រុមនីមួយៗបានធ្វើលំហាត់ចប់។ លោកអ្នកគួរតែធ្វើកំណត់សំគាល់នៃចំណុចល្អ និងអាក្រក់ផង ដែរ

ដើម្បីឱ្យអ្នកអាចលើកចំណុចទាំងនេះ យកមកពិភាក្សាជាទូទៅនៅពេលចប់លំហាត់។ ចូរបញ្ជាក់បន្ថែមនូវចំណុចល្អៗដែលក្មេងៗទទួលបាន ហើយប្រើប្រាស់ការរិះគន់កែលំអ ចំពោះចំណុចទាំងឡាយណាដែលពួកគេធ្វើមិនសូវបានល្អ។ វាប្រាកដជាបទពិសោធន៍ដែលបានពីការសិក្សា ពួកគេនឹងទទួលប្រយោជន៍ដ៏ធំធេងពីការសម្តែងតួរនេះនៅក្នុងលក្ខខណ្ឌនៃការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ។

ប្រសិនបើលោកអ្នកចង់ (ហើយប្រសិនបើអ្នកមានអារម្មណ៍ថា អាចទទួលបានល្អ) បង្កើនការប្រលងប្រណាំងតូចៗរវាងក្រុម និងក្រុមដើម្បីធ្វើឱ្យមានការចាប់អារម្មណ៍ថែមទៀត និងបង្ហាញពីការកំប្លែងឧទាហរណ៍

- រង្វាន់សម្រាប់ការសំដែងតួដែលល្អជាងគេ ( ការប្រលងប្រណាំងដើម្បីវាស់កម្រិតក្រុម )។
- រង្វាន់សម្រាប់សម្តែងតួដែលកំប្លែងជាងគេបំផុត។

## ការសម្ភាសន៍

នៅពេលអ្នកបានធ្វើលំហាត់ចប់អ្នកគួរតែឱ្យក្រុមបញ្ចប់នូវរបៀបដោះស្រាយទៅកាន់ស្ថានីយ៍ វិទ្យុ និងទូរទស្សន៍ក្នុងស្រុក ហើយធ្វើសម្ភាសន៍ពិតប្រាកដ។ ជាក់ស្តែងសមាជិកក្រុមម្នាក់ៗមិនអាចសម្ភាសន៍ទាំងអស់ទេ។ អ្នកអាចមានសំណាង ប្រសិនបើលោក អ្នកទទួលការចូលរួមពីបុគ្គលដែលមានគ្នាលើសពីពីរនាក់ ហើយអាចថា ស្ថានីយ៍វិទ្យុ ទូរទស្សន៍ក្នុងស្រុកនឹងត្រូវការវត្តមានរបស់អ្នកមកធ្វើជាអ្នកដឹកនាំគម្រោងផងដែរ។ ដូច្នេះហើយអ្នកត្រូវស្វែងរកឱ្យបានត្រឹមត្រូវ និងឱ្យច្បាស់លាស់នូវរបៀបនៃការជ្រើសរើសមនុស្សដើម្បីធ្វើសម្ភាសន៍។ លទ្ធភាពមួយដែលអាចកើតឡើងប្រមូលឈ្មោះរបស់មនុស្សដែលចង់ទៅសម្ភាសន៍ទាំងនោះ បន្ទាប់មកដកឈ្មោះដែលមិនសំខាន់ចេញ។ អ្នកខ្លះមុខតែនឹងខកចិត្តប៉ុន្តែពួកគេប្រហែលជាមានឱកាសនៅពេលក្រោយ។ នៅពេលគេកំណត់បានកាលបរិច្ឆេទ និងពេលវេលារួចហើយ លោកអ្នកគួរតែធ្វើមេរៀនសង្ខេបជាមួយអ្នកដែលពាក់ព័ន្ធ ហើយជួយពួកគេឱ្យមានអារម្មណ៍ធូរស្រាល។ អានកំណត់សំគាល់របស់អ្នកពីលំហាត់សម្តែងតួ ហើយបញ្ជាក់បន្ថែមទៅលើចំណុចវិជ្ជមានដែលពួកគេគួរចងចាំ។ ចូរធានាឱ្យប្រាកដថា ពួកគេយល់ច្បាស់ ចំពោះព័ត៌មានដែលពួកគេចង់ស្វែងយល់។ ចូរ

ចូរមកដល់មុនពេល សម្រាប់ការ សម្ភាសន៍ ហើយបញ្ជាក់ឱ្យច្បាស់ថា ក្រុមត្រូវអរគុណអ្នកសម្ភាសន៍ និងអ្នកផលិតនៅពេលចប់។ រក្សាក្រុមទាំងអស់ឱ្យនៅជុំគ្នាបន្ទាប់ពីសម្ភាសន៍ចប់។ ប្រហែលជាត្រូវផ្តល់ភេសជ្ជៈខ្លះៗដល់ពួកគេនៅកន្លែងណាមួយ ហើយមានការសប្បាយរីករាយនឹងរំលឹកមេរៀន។ ដូច្នេះហើយគេបាន (បន្ថយភាពតានតឹង) និងអាចយកខ្យល់អាកាសបរិសុទ្ធ។ ពួកគេនឹងត្រូវស្វែងរកផ្លូវចេញមួយសម្រាប់បញ្ចេញកម្លាំងច្រួលច្រាលដែលបានកើតឡើង។

ប្រសិនបើស្ថានីយ៍វិទ្យុ ឬ ទូរទស្សន៍មិនអាចផ្តល់កាសែតសម្លេង ឬកាសែតវីដេអូ សម្រាប់ការសម្ភាសន៍ឱ្យអ្នកទេ? ចូរឱ្យប្រាកដថា មានក្រុមមួយគឺកំពុងស្តាប់ ហើយនឹងថតការសម្ភាសន៍នេះជាសម្លេង។

ចូរពិនិត្យឱ្យច្បាស់ថា អ្នកបានប្រាប់ពួកគេនូវការងារដ៏ល្អដែលគេបានធ្វើកន្លងមក។ ចូរជួយជ្រោមជ្រែងឱ្យគេមានជំនឿជឿជាក់ ហើយអរគុណដល់គេទាំងអស់គ្នាដែលបានចូលរួម ។ប្រាប់ឱ្យគេចាត់តាំងតំណាងក្រុមម្នាក់សរសេរសំបុត្រថ្លែងអំណរគុណដល់ស្ថានីយ៍វិទ្យុបន្ទាប់ពីចប់ការសម្ភាសន៍។ ថែរក្សាទំនាក់ទំនងយ៉ាងល្អជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយពិតជាមានសារៈសំខាន់ណាស់ ។



**អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ**

- ចូរធ្វើឱ្យប្រាកដថា បុគ្គលម្នាក់ៗបានចូលរួមក្នុងគ្រប់មេរៀននៃជំពូកនេះ
- ត្រូវប្រើភាពកំប្លុកកំប្លែង និងភាពសប្បាយរីករាយ ការនិយាយលេងសើចជាមួយគ្នា ដើម្បីជួយមេរៀនឱ្យបានល្អ។ គេអាចប្រើការប្លែងក្នុងការសំដែងដែលគេបានធ្វើ ឧទាហរណ៍ ប្រហែលជាមាននរណាម្នាក់ធ្វើត្រាប់តាមបុគ្គលិកលក្ខណៈមួយនៅតាមវិទ្យុដែលល្បីល្បាញ។
- កុំបណ្តោយក្រុមឱ្យមើលស្រាលលើការងាររបស់ក្រុមដទៃផ្សេងទៀត។ ពួកគេសមនឹងទទួលការគោរព និងការយកចិត្តទុកដាក់។
- ចូរបន្តរក្សាការថតវីដេអូ ឬថតកាសែត ដែលថតយកការសម្ភាសន៍ ប្រសិនបើលោក អ្នកមានសំភារៈប្រភេទនេះ។
- កុំបង្ខំបុគ្គលណាមួយឱ្យធ្វើអ្វីមួយដែលគេពិតជាមិនពេញចិត្តធ្វើជាមួយ ឬ មិនអាចធ្វើបាន។ មនុស្សខ្លះមិនអាចដោះស្រាយជាមួយនឹងការបង្ហាញនូវការពិត

ជាសាធារណៈ ហើយអ្នកត្រូវថ្លឹងថ្លែងគិតគូរដល់អារម្មណ៍របស់ពួក គេ។

- កុំធ្វើការប្រលងប្រណាំងតូចតាច ដែលអ្នកគិតថា ប្រើច្រើនពេកទិសដៅដែលមានរយៈពេលខ្លី។ ប្រសិនបើអ្នកគិតថា កត្តាទាំងនេះអាចបណ្តាលឱ្យមានបញ្ហាច្រើន ឬធ្វើឱ្យក្រុមបាត់បង់ភាពរឹងមាំ ចូរកុំប្រើវា។



## ការពិភាក្សាបញ្ចប់

*បង្រៀនមួយពេល*

ចូរឱ្យមានការពិភាក្សាបញ្ចប់របស់អ្នក ពេលមនុស្សគ្រប់គ្នាបានសំដែងតួរបស់ខ្លួន។ ការងារជាមួយប្រព័ន្ធផ្សព្វផ្សាយជាពិសេសជាមួយវិទ្យុ និង ទូរទស្សន៍ គឺជាក្តីសង្ឃឹមដ៏គួររំភើប ហើយក្មេងៗនៅក្នុងក្រុមរបស់អ្នកប្រហែលជាឆ្លើយតបយ៉ាងល្អចំពោះជំពូកនេះមានការរំភើបយ៉ាងខ្លាំងប្រសិន បើអ្នកបានទទួលជោគជ័យក្នុងការទទួលយកការសម្ភាសន៍តាមវិទ្យុ និងទូរទស្សន៍។ ពួកគេនឹងចូលចិត្តគំនិតដែលមានមុខតាមវិទ្យុ និងកញ្ចក់ទូរទស្សន៍ ហើយគំនិតមនុស្សក្នុងសហគមន៍របស់ពួកគេយល់ដឹងច្រើនអំពីអ្វីដែលគេកំពុងសិក្សា និង កំពុងធ្វើថែមទៀត។ ចូរកុំភ្លេចថតចម្លងការសម្ភាសន៍ចេញពីវិទ្យុ និងទូរទស្សន៍ ហើយថែរក្សាវាទុកជាផ្នែកមួយនៃការផ្សព្វផ្សាយដែលកាត់ចេញពីលំហាត់។ ចាក់សារឡើងវិញឱ្យក្រុមរបស់អ្នកស្តាប់ទុកជាផ្នែកមួយនៃដំណើរការប្រមូលព័ត៌មាន។

ដូច្នេះហើយជួយរក្សាភាពរំភើប និងការចាប់អារម្មណ៍ក្នុងក្រុមដោយត្រូវបានធ្វើឱ្យសកម្មឡើងក្នុងការបញ្ចប់មតិយោបល់របស់អ្នក។ ចូរឱ្យពួកគេបានដឹងអំពីការឆ្លើយតបរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ តាមមូលដ្ឋានដែលថានរណាជាអ្នកដឹងអ្នកអាចបង្កើតទូរទស្សន៍ជាតិ ដែលជាផែនការសម្រេចជោគជ័យពិតសម្រាប់គម្រោងរបស់អ្នក និងជួយជ្រោមជ្រែងយ៉ាងខ្លាំងដល់ក្រុមមនុស្សក្មេងៗដែលនៅក្នុងក្រុមរបស់អ្នក។ វាពិតជាអ្វីមួយដែលយើងរំពឹងរង់ចាំ ហើយវានឹងផ្តល់នូវវិសាលភាពដ៏ធំសម្រាប់ការងារបន្តក្រោយៗបន្ត។ ចូរកុំភ្លេចការគាំទ្រឧបត្ថម្ភដែលអាចមើលឃើញមួយចំនួន ដែលលោកអ្នកអាចប្រើប្រាស់បានតាម

កញ្ចក់ទូរទស្សន៍ដូចជារូបភាពផ្សេងៗដែលត្រូវបានផលិតឡើងនៅក្នុងការប្រលងប្រជែងផ្នែកសិល្បៈ។



## ការវាយតម្លៃ និងសកម្មភាពបន្ត

ក្នុងលក្ខខណ្ឌអាំងឌីកាទ័រសម្រាប់ជំពូកនេះ មានលទ្ធផលជាក់លាក់ដែលអាចវាស់បានមកដល់ពេលនេះ ព្រោះថា វានឹងត្រូវកើតឡើង ឬអាចមិនកើតឡើងនូវក្រុមតូចៗ បង្កើតឆាកសំដែងនៃការសម្ភាសន៍តាមវិទ្យុ ឬទូរទស្សន៍ ។ គុណភាពនៃការងារនឹងអាស្រ័យទៅលើទំហំនៃជំពូកមេរៀនដែលត្រូវបានអនុវត្តបានល្អដោយរបៀបណា និងទំនាក់ទំនងដែលអ្នកអាចមានលទ្ធភាពបង្កើតឡើងជាមួយក្រុម។

ចំពោះអាំងឌីកាទ័រផ្សេងទៀតរួមមាន :

- កសាងទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍នៅថ្នាក់មូលដ្ឋាន ( ឬថ្នាក់តំបន់ និងថ្នាក់ជាតិ )
- បញ្ជូនការផ្សព្វផ្សាយព័ត៌មានទៅប្រព័ន្ធផ្សព្វផ្សាយ។
- ការអ្នកមិនត្រូវតែទទួលបានការសម្ភាសន៍តាមវិទ្យុក៏បានតាមទូរទស្សន៍ក៏បានប៉ុណ្ណោះទេ ក៏ប៉ុន្តែក្រុមអ្នកអាចត្រូវបានគេផ្តល់ការសម្ភាសន៍អំពីគម្រោងដែលពាក់ព័ន្ធនឹងគម្រោងកម្មវិធី កម្មវិធីយុវជន
- បង្កើតសកម្មភាពបន្តក្នុងសញ្ញាសកម្មភាពសម្ភាសន៍ បន្ទាប់ពីការសម្ភាសន៍នេះ។

ម៉ូឌុលទាំងអស់នេះ គឺទាក់ទងនឹងការផ្លាស់ប្តូរចូលទៅក្នុងដំណាក់កាលសកម្មភាពនៃការចូលរួមនៅក្នុងយុទ្ធនាការពិភពលោក ដើម្បីលុបបំបាត់ពលកម្មកុមារ។ ដូច្នេះអាំងឌីកាទ័រខាងលើ មានសារៈខាន់ខ្លាំងណាស់ក្នុងការកំណត់ថាតើក្រុមរបស់អ្នកស៊ូប្តូរក្នុងការចាត់វិធានការចូលរួមក្នុងបញ្ហា និងគម្រោងនោះត្រឹមកម្រិតណា។ លទ្ធផលសកម្មភាពនេះនឹងមានសារៈសំខាន់សម្រាប់អ្នកក្នុងលក្ខខ័ណ្ឌនៃការវាយតម្លៃផ្ទាល់ខ្លួនលើការអនុវត្តជំពូកនេះ ដើម្បីកំណត់ថ្ងៃ ខែ និងវាយតម្លៃការចូលរួមរបស់ក្រុម និងបុគ្គលដែលចូលរួមក្នុងក្រុម។ ពេលនេះ អ្នកគួរតែស្គាល់ឱ្យប្រាកដបុគ្គលដែលពិតជាប្តេជ្ញាចិត្តសម្រេចនូវគម្រោងនេះ និងសម្រេចនូវគោលបំណងដើម្បីលើកកំពស់នូវការយល់ដឹងអំពីពលកម្មកុមារ និងត្រូវធ្វើអ្វីម្យ៉ាងដែលទាក់ទងនឹងបញ្ហានេះ។

ម៉ូឌុលដោយឡែកនេះ គឺជាគន្លឹះសម្រាប់ការអប់រំដល់ក្រុមក្មេងៗរបស់លោក អ្នក។ សកម្មភាពនៅក្នុងម៉ូឌុលនេះបង្ហាញនូវរបៀបដែលពួកគេអាចចាត់វិធានការលើកកំពស់ការយល់ដឹងអំពីបញ្ហាពលកម្មកុមារ។ ពួកគេអាចសំដែងនូវអារម្មណ៍របស់ពួកគេដល់សហគមន៍ណាដែលធំទូលាយជាងនេះ និងបង្ហាញថានរណាដឹងពីទីកន្លែងដែលព័ត៌មានរបស់ពួកគេត្រូវផ្សាយចេញមកពួកក្រុម និងបុគ្គលដទៃផ្សេងទៀតក៏ប្រហែលជាកសាងនូវចំណាប់អារម្មណ៍ និងបង្កើតទំនាក់ទំនងផងដែរ។ អាជ្ញាធរដែលទទួលបន្ទុកផ្នែកអប់រំតាមមូលដ្ឋានប្រហែលជាចាប់អារម្មណ៍ទៅលើអ្វីដែលពួកក្មេងៗកំពុងធ្វើនេះ។ ការទទួលសារព័ត៌មានចេញទៅក្នុងប្រព័ន្ធផ្សព្វផ្សាយអាចចាប់ផ្តើម ដើម្បីបើក ចំហរទ្វារដ៏ច្រើន។ ជំពូកនេះ គឺបញ្ជាក់បន្ថែមទៀតអំពីសារព័ត៌មាននៃក្តីសង្ឃឹមសម្រាប់ក្រុម។ ពួកគេយល់ឃើញថា អ្វីៗគ្រប់យ៉ាងមិនសុទ្ធតែគ្មានសង្ឃឹមនោះទេ ពោលគឺមានវិធី និងមធ្យោបាយសម្រាប់ពួកគេដើម្បីចាត់វិធានការដែលទទួលផលវិជ្ជមាន។ ការងារនេះពិតជាអាចផ្តល់នូវឥទ្ធិពល និង ប្រសិទ្ធិភាពខ្ពស់ប្រសិនបើយើងរៀបចំ និងចាត់ការបានល្អ។ ប្រសិនបើការសម្ភាសន៍នេះត្រូវធ្វើឡើង ចូរលោក អ្នកធានាឱ្យប្រាកដថា លោក អ្នកបណ្តុះ នូវមោទនៈភាព និងភាពជឿជាក់របស់ពួកគេដើម្បីចាត់វិធានការអនុវត្តសកម្មភាពបន្តទៀត។ ព្រមទាំងជំរុញនូវការលើកទឹកចិត្តនៅពេលដែលអ្នកបានបំពេញបញ្ចប់ម៉ូឌុលនេះទៅតាមតម្រូវការរបស់អ្នក

ចូរបន្តទៅម៉ូឌុលថ្មីមួយទៀត។ ពួកយើងសូមផ្តល់ជាអនុសាសន៍ថា ជំពូកក្រោយៗទៀតដែលលោក អ្នកអនុវត្តត្រូវនាំយកក្រុមឱ្យចូលទៅក្នុងផ្នែកផ្សេងទៀតនៃយុទ្ធនាការ ឧទាហរណ៍ដូចជាការនាំចូលតាមរយៈម៉ូឌុល សមាហារណកម្មសហគមន៍។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡុង សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | |
|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម |
| ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល |
| ៤_លោក តេះ ដាវី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការផ្ទៀងផ្ទាត់

| | |
|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម |
| ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី វ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


## សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឌីរ ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេខ ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217

9 789995 088217